# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាមិទកម្មវិធីបូជនីយេសក៍នៅគីរីវង់
# ថ្ងៃទី១៩ វិច្ឆិកា ២០១៧
# *បម្រើដោយទទួលខុសត្រូវយ៉ាងខ្ពស់*

អត្ថបទទី១៖ សុភ ៣១,១០-១៣.១៩-២២.៣០-៣១
អត្ថបទទី២៖ ១ថស ៥,១-៦
ដំណឹងល្អ៖ មថ ២៥,១៤-៣០

បងប្អូនជាទីស្រឡាញ់!

ពីមួយឆ្នាំទៅមួយឆ្នាំ ពេលយើងធ្វើបូជនីយេសក៍ ជួនកាលជាឱកាសមួយដើម្បីនឹកឃើញដល់មរណៈសាក្សី ជួនកាលជាឱកាសមួយដើម្បីនឹកឃើញដល់ការបង្កើតព្រះសហគមន៍។ សម្រាប់ឆ្នាំនេះ ដែលយើងបានដើរពីព្រះសហគមន៍ចំការទៀង ដល់ព្រះសហគមន៍នៅគីរីវង់ ជាឱកាសមួយដើម្បីយល់ដែរ ពីប្រវត្តិសាស្ត្រនៃព្រះសហគមន៍ ដែលមាននៅភូមិភាគភ្នំពេញ។ ភូមិភាគភ្នំពេញ មុនសម័យប៉ុលពតអត់សូវមានព្រះសហគមន៍ប៉ុន្មានទេ នៅសម័យអាណានិគមបារាំង យើងមានព្រះវិហារតាមទីរួមខេត្តនីមួយៗទូទាំងប្រទេស។ ប៉ុន្តែមិនមែនព្រះវិហារសម្រាប់ខ្មែរប៉ុន្មានទេ ដោយសារនៅទីរួមខេត្តមួយៗគេមានបារាំងដែលស្នាក់នៅគេដាក់ព្រះវិហារមួយ។ នៅឆ្នាំ១៩៦០ យើងមានព្រះវិហារមួយនៅទីរួមខេត្តតាកែវ ប៉ុន្តែអត់ដែលមានសកម្មភាពប៉ុន្មានទេ។ មុនឆ្នាំ១៩៧០ គេចាប់ផ្តើមជាមួយមណ្ឌលទទួលយុវនារី មណ្ឌលកាត់ដេរ និងថែទាំយុវនារី។ នៅខេត្តកំពត យើងមានព្រះវិហារមួយនៅខាងលិចរង្វង់មូលធូរ៉េន កន្លែងមានការ៉ាសសាំង មានលោកឪពុកម្នាក់ដែលពូកែខាងវិស្វករ និងគាត់គូររូបព្រះវិហារដែលយើងស្គាល់នៅកំពង់សោម។

នៅក្នុងភូមិភាគភ្នំពេញ មុនឆ្នាំ១៩៧០ មានវៀតណាមជាង៦ម៉ឺននាក់ បងស្រីឧបការគុណមាន១៨០នាក់ និងលោកសាសនទូតនិយាយវៀតណាមច្រើនជាងនិយាយខ្មែរ។ ប៉ុន្តែឆ្នាំ១៩៧០ មានវៀតណាមមួយចំនួនធំដែលទៅវៀតណាមវិញ នៅពេលនោះនៅសល់ខ្មែរតិច ពីរបីពាន់នាក់ នៅភូមិភាគភ្នំពេញអត់មានប្រវត្តិសាស្ត្រចូលយ៉ាងជ្រៅ នៅតាមជនបទនៅតាមកម្មវិធីផ្សេងៗ មានតែព្រះវិហារសម្រាប់ខ្មែរតែមួយគត់ គឺព្រះវិហារព្រះមាតានៅជិតផ្សារតូច សព្វថ្ងៃជាមណ្ឌលសុខភាពមួយដែលមានរូបព្រះនាងម៉ារី។ ប៉ុន្តែពីឆ្នាំ១៩៩០ នៅពេលសាសនទូតត្រលប់មកវិញ យើងចាប់ផ្តើមសាងសង់ព្រះសហគមន៍សារជាថ្មី និងនៅឆ្នាំ២០០១ លោកអភិបាលអេមីល គាត់បានសម្រេចចិត្តធ្វើយ៉ាងណាឲ្យមានព្រះសហគមន៍

សារជាថ្មី ជាពិសេសនៅតាមភូមិ នៅក្នុងខេត្តកំពត-តាកែវ។ គាត់ផ្ញើខ្ញុំនិងលោកលី ទៅកំពត-តាកែវ ដូច្នេះយើងស្នាក់នៅកំពតពីរនាក់ និងលោកឪពុកលីទៅជុំគិរី ជាគ្រួសារតែមួយដែល បានទទួលពិធីជ្រមុជទឹកនៅក្នុងជំរុំនៅឆ្នាំ១៩៩៣។ នៅចំការទៀងជាមួយលោកកុល ជៀង ជាគ្រីស្តបរិស័ទម្នាក់ដែលទទួលជ្រមុជទឹកនៅឆ្នាំ១៩៩៨។

នៅខេត្តតាកែវ ពេលខ្ញុំទៅដល់នៅឆ្នាំ២០០១ ២០០២ មានគ្រីស្តបរិស័ទតែម្នាក់គត់ លោកគ្រូ កុល ជៀង បុណ្យព្រះយេស៊ូប្រសូតនៅឆ្នាំ២០០១ មានយុវជនតិចៗ គាត់ធ្លាប់ប្រមូលយុវជនមកជួបជុំគ្នាអប់រំជំនឿមួយចំនួន និងយុវជនដែលខ្ញុំស្គាល់មុនគេបង្អស់គឺ សារឿន ដោយសារនៅយប់នោះខ្ញុំឲ្យសារឿន ៨0ដុល្លា ដើម្បីធ្វើការីនំប៉ុង ប៉ុន្តែពេលធ្វើការីនំប៉ុង គាត់និយាយមកខ្ញុំ "លោកឪពុក! ខ្ញុំឃ្លានណាស់ មូលហេតុអ្វីមិនឲ្យញុំាំឆ្អែត?"។ នៅឆ្នាំ២០០២ យើងបានធ្វើជំហានទី១ ឲ្យយុវជនមួយចំនួនដូចជា ហ៊ុនអាន មាឃស៊ន កែវភោគ ស៊ាន់សារឿន ...។ នៅពេលខ្ញុំចាប់ផ្តើមអភិបូជានៅឆ្នាំ២០០២ នៅចំការទៀងរាល់អាទិត្យខ្ញុំឃើញ លោកតាចយ និងលោកតា សុខ ដែលធ្វើដំណើរពីភូមិព្រៃជើងនៅគិរីវង់នេះទៅដល់ព្រះវិហារចំការទៀង។ សម័យនោះផ្លូវពិបាក ធ្វើដំណើរមួយម៉ោងពីរម៉ោងយ៉ាងតិច និងគាត់ចូលព្រះវិហារមួយភ្លែតគាត់ទៅវិញ។

ឆ្នាំ២០០៣ ខ្ញុំនិយាយជាមួយលោកតា ខ្ញុំចង់ស្គាល់កន្លែងលោកតាម្តង ដូច្នេះគាត់អញ្ជើញខ្ញុំមកទីនេះ ខ្ញុំធ្វើដំណើរជាមួយម៉ូតូធំធ្វើដំណើរដល់ផ្ទះយុវជនម្នាក់ និងពេលនោះខ្ញុំភ្ញាក់ដោយសារលោកតា បានប្រមូលមនុស្សច្រើនណាស់ មានតាមានយាយ មានយុវជនមានទាំងអស់គ្នាដែលលកំពុងឈរមើលខ្ញុំ អត់ដឹងនិយាយអី ខ្ញុំភ័យណាស់ ព្រោះខ្ញុំនិយាយខ្មែរតិចៗ និងយាយៗគាត់ឃើញខ្ញុំ គាត់គិតថាខ្ញុំជាលោកគ្រូពេទ្យមកពីពេទ្យយេស៊ូ ហើយគេបង្ហាញថា គេឈឺសរសៃ ឈឺខ្នង ឈឺជង្គង់...។ ក្រោយមក យើងចាប់ផ្តើមនៅផ្ទះលោកតា ជាមួយយុវជនខ្លះៗ ចាប់ផ្តើមអប់រំជំនឿជាមួយលោកគ្រូតាវ ដែលមកពីបាត់ដំបង បូរ៉ា និងក្រោយមកយើងបន្តជាមួយកែវ ភោគ សារឿន និង វិចិត្រ និងរាល់អាទិត្យខ្ញុំមកដើម្បីអធិដ្ឋាននៅផ្ទះលោកតា ដោយសាអត់មានគ្រីស្តបរិស័ទ។

នៅឆ្នាំ២០០៥ លោកតា បានទទួលអគ្គសញ្ញាជ្រមុជទឹក និងក្រោយមកឆ្នាំ២០០៧ ឆ្នាំ២០០៩ ឆ្នាំ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ ឆ្នាំ២០១៧ មានអគ្គសញ្ញាជ្រមុជទឹកព្រោះយើងធ្វើ២ឆ្នាំម្តង។

នៅឆ្នាំ២០០៦ យើងចាប់ផ្តើមសាលាមត្តេយ្យ ជាមួយស្រីឡុក និងស្រីម៉ាច ប៉ុន្តែសាលាមត្តេយ្យយើងចាប់ផ្តើមនៅផ្ទះលោកតា។ ប៉ុន្តែនិយាយពីការចាប់ផ្តើមព្រះសហគមន៍មិនស្រួលទេ ពេលយើងចាប់ផ្តើមទទួលការរិះគន់ច្រើន និងប៉ុន្មានដងយើងលឺនៅតាមមេក្រូ អាចារ្យនិយាយថាប្រយ័ត្ន បើសិនជាលោកតាលោកយាយ ឲ្យកូនៗចូលព្រះវិហារ យើងឈប់អនុញ្ញាតឲ្យរៀបការ យើងឈប់អនុញ្ញាតឲ្យមានអំណោយផ្សេងៗ។ ខ្ញុំបានទិញដីនេះជាលើកទី១ដែលយើងធ្វើបុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍នេះក្នុងឆ្នាំ២០០៦ អត់ទាន់មានព្រះវិហារទេ ហើយយើងបានប្រមូលយុវជននៅទីនេះ យើងបានអញ្ជើញលោកតាលោកយាយផង។ យើងបានទិញមុង ភួយ ម្សៅ... ជូនជាកាដូរបន្តិចបន្តួច ដល់លោកតាលោកយាយ។ ពីពេលនោះ ក៏លែងមានការរិះគន់ទៀត ផ្ទុយទៅវិញមានយាយមួយចំនួនចូលព្រះវិហារ កូនចៅនៅខាងមុខនិងយាយៗនៅខាងក្រោយ។ នៅពេលនោះចាប់ផ្តើមទំនាក់ទំនងជាមួយប្រជាជនស្រួលណាស់ តាមរយៈគណៈកម្មាការសង្គហៈ ជួយអ្នកក្រីក្រខ្លះ អ្នកជំងឺខ្លះ កូនក្មេង និងចាប់ផ្តើមជាមួយកាយឫទ្ធិនិងកម្មវិធីផ្សេងៗ។

នៅឆ្នាំ២០០៨ យើងបានសាងសង់សាលាមត្តេយ្យ និងព្រះវិហារនៅទីនេះ និងបានសម្ពោធពេលខ្ញុំជាលោកអភិបាលនៅឆ្នាំ២០១០។ ដូច្នេះនេះជាប្រវត្តិសាស្ត្រសង្ខេប អំពីព្រះសហគមន៍មួយដែលបានកើតឡើងនៅក្នុងគិរីវង់ ប៉ុន្តែចាប់ផ្តើមនៅចំការទៀង ជាមួយលោកគ្រូ កុល ជៀងម្នាក់។ ពីគិរីវង់ យើងចាប់ផ្តើមបន្តទៅព្រៃកប្បាស ដល់ទ្រាំមខេត្តតាកែវ ហើយដល់សន្តប៉ូល ដល់កំពង់អំពិល ដល់ត្រពាំងក្រញូង ដល់ទន្លេបាទី តាមពិតចំការទៀតក៏ជាអ្នកបង្កើតព្រះសហគមន៍កោះស្លានៅកំពតដែរ។ ដូច្នេះពីលោកគ្រូ កុល ជាង ជាគ្រីស្តបរិស័ទម្នាក់ បានចាប់ផ្តើមព្រះសហគមន៍៨កន្លែងនៅក្នុងខេត្តតាកែវ និង១នៅក្នុងខេត្តកំពត។ នេះជាជីវិតនៃព្រះសហគមន៍ និងអរគុណលោកតាដែលបានឆ្លងឧបសគ្គមួយចំនួន បានលីឈើឆ្កាងម្តងៗដែរ តែបានលទ្ធផលមានផ្លែ មានអំណរសប្បាយ មានគ្រីស្តបរិស័ទច្រើនមានកូនចៅតៗគ្នា។

ព្រះវិហារនេះមានឈ្មោះ ព្រះត្រៃឯក ជាឈ្មោះដែលលោកតាដាក់ឲ្យ ដោយសារពេលសាងសង់វិហារនេះ ខ្ញុំធ្វើដំបូល៣ជាន់ មានដំបូលទាប កណ្តាល និងខ្ពស់ ហេតុនេះហើយដាក់ឈ្មោះព្រះត្រៃឯក មានន័យថាព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ជាអង្គតែមួយ។ ល្អស្តាប់ដែរដោយសារ លោកគ្រូ ជៀង ពេលទទួលអគ្គសញ្ញាជ្រមុជទឹកមានឈ្មោះ ប៉ូល និងលោកតា ឈ្មោះ សិលា ដូច្នេះ សន្តប៉ូល និងសន្តសិលា ជាអ្នកបង្កើតព្រះសហគមន៍នៅក្នុងខេត្តតាកែវទាំងមូល ណែនាំឲ្យយើងត្រូវតែអរព្រះគុណព្រះជាម្ចាស់។ ខ្ញុំគិតថា ជាកម្លាំងមួយសម្រាប់គ្រីស្តបរិស័ទ និងយុវជនទាំងអស់ដោយដឹងថាយើងត្រូវតែបន្តប្រកាសដំណឹងល្អ ដោយទទួលខុសត្រូវយ៉ាងខ្ពស់។ អត្ថបទគម្ពីរដែលយើងស្តាប់ថ្ងៃនេះជា អត្ថបទគម្ពីរមួយដែលត្រូវការរំលឹកអំពីតួនាទីរៀងៗខ្លួន "**ម្ចាស់ដែលបានចេញដំណើរ**" មុនចេញដំណើរគាត់បានប្រមូលអ្នកបម្រើរបស់គាត់ និងគាត់ចែកទ្រព្យសម្បត្តិខ្លះៗ មានម្នាក់ដែលទទួល៥ណែន ម្នាក់ទៀតបានទទួល២ និងម្នាក់ទៀតបានទទួល១ បានទទួល៥ ២ ឬ១ មិនសំខាន់ប៉ុន្មានទេ តែអ្វីដែលសំខាន់គឺម្ចាស់ផ្ទះបានទុកចិត្តលើគេ។ គាត់បានរើសអ្នកបម្រើគាត់ និងគាត់ទុកចិត្តអ្នកបម្រើហ្នឹង គាត់សង្ឃឹមអ្នកបម្រើហ្នឹងទទួលខុសត្រូវយ៉ាងខ្ពស់។ ក្រោយមកគាត់ចេញធ្វើដំណើរ ពេលត្រលប់មកវិញគាត់ចង់មើលលទ្ធផល នៃការទទួលខុសត្រូវនៃអ្នកបម្រើរបស់គាត់។ ដូច្នេះអ្នកបម្រើទីមួយបានសងគាត់១០ណែន និងអ្នកទីពីរបានសងគាត់៤ណែន និងអ្នកទីបីបានសងគាត់១ណែន។ ដូច្នេះ អ្នកទីមួយបានសងគាត់គុណជាពីរ អ្នកទីពីរគុណជាពីរ ឯអ្នកទីមួយគឺដដែល។

ដូច្នេះ ថ្ងៃនេះឲ្យយើងមើលនេះ យើងម្នាក់ៗព្រះជាម្ចាស់បានជ្រើសរើសយើងរៀងៗខ្លួន យើងបានទទួលការត្រាស់ហៅមួយ យើងជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍ផ្សេងៗ យើងជាយុវជន កូនក្មេង នៅព្រះសហគមន៍គិរីវង់ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីទៅជាអ្នកបម្រើដែលទទួលខុសត្រូវយ៉ាងច្បាស់លាស់ គឺទទួលខុសនិងត្រូវ។ អាដាំ និងអេវ៉ា តួនាទីទីមួយគឺទទួលខុសត្រូវមានកូន តួនាទីទីពីរគឺទទួលខុសត្រូវលើផែនដីទាំងមូល មិនមែនតែថែរក្សា ប៉ុន្តែទទួលខុសត្រូវផែនដីទាំងមូល ទាំងសង្គម ទាំងផែនដី ដើម្បីប្រទេសនីមួយៗ ដើម្បីភូមិនីមួយៗ ដើម្បីកន្លែងមួយៗ គ្រួសារមួយៗមានការរីកចម្រើន នេះជាការទទួលខុសត្រូវ។ ម្ចាស់ដែលឲ្យ ៥ ២ និង១ គឺគាត់ចង់ឲ្យអ្នកបម្រើរបស់គាត់ទទួលខុសត្រូវដើម្បីឲ្យទ្រព្យសម្បត្តិហ្នឹងរីកចម្រើន។ ដូច្នេះបញ្ហាកើតឡើង ជាមួយអ្នកទីបី

ដោយសារ អ្នកទីបីគាត់បានទទួល១ណែន ប៉ុន្តែគាត់អត់មានអ្វីថែមទៀតទេ គាត់អត់បានចាយ តែផ្ទុយទៅវិញគាត់ភ័យដោយសារគាត់គិតថា ម្ចាស់របស់គាត់តឹងរឹង កាច ដូច្នេះគាត់កប់លុយដែលគាត់មាន គាត់បានលាក់ទុក ដល់ពេលដែលម្ចាស់របស់គាត់ត្រលប់មកវិញ គាត់សប្បាយចិត្ត គាត់គិតថា គាត់ធ្វើល្អ ដោយសារគាត់អត់បានធ្វើឲ្យបាត់។ អត់បានបាត់ពិតមែន តែគាត់មិនបានធ្វើឲ្យរីកចម្រើនសោះ ជាមូលហេតុដែលម្ចាស់នោះឃើញហើយក៏បណ្តេញគាត់ ដោយសារគាត់អត់បានទទួលខុសត្រូវលើទ្រព្យសម្បត្តិដែលគាត់បានទទួល។ គាត់មិនបានធ្វើឲ្យយ៉ាងម៉េចឲ្យរីកចម្រើន គាត់ទុកដដែល ហើយនៅពេលយើងទុកដដែលធ្វើយ៉ាងម៉េចអាចអភិវឌ្ឍន៍បាន? អភិវឌ្ឍន៍ជីវិតរបស់យើង អភិវឌ្ឍន៍ប្រទេសរបស់យើង អភិវឌ្ឍន៍ព្រះសហគមន៍របស់យើង យើងធ្វើយ៉ាងម៉េចបើសិនយើងជាមនុស្សដែលចាំតែអង្គុយថែរក្សាទ្រព្យសម្បត្តិដែលយើងទទួលពីយូរហើយ មិនធ្វើឲ្យរីកចម្រើនអ្វីសោះ។

ពេលខ្ញុំបង្ហាញពីជីវិតនៃព្រះសហគមន៍ក្នុងខេត្តតាកែវ យើងឃើញព្រះសហគមន៍ចាប់ផ្តើមពីគ្រីស្តបរិស័ទម្នាក់។ សព្វថ្ងៃយើងមានរាប់រយ ដោយសារនៅចំការទៀងយើងមាន៣០០នាក់ នៅគិរីវង់នេះមាន១៥០នាក់ នៅតាមកន្លែងនីមួយៗចាប់ផ្តើមមានដែរ។ ប្រសិនបើម្នាក់នោះ (លោកគ្រូ កុល ជៀង) បានទុកជំនឿសម្រាប់ខ្លួនគាត់ផ្ទាល់ និងអត់បានយកចិត្តទុកដាក់ប្រមូលយុវជាជន ឲ្យគេស្គាល់ព្រះយេស៊ូខ្លះ ឲ្យគេច្រៀង ស្តាប់ព្រះគម្ពីរខ្លះ ព្រះសហគមន៍នៅដដែល ប៉ុន្តែគាត់បានធ្វើឲ្យព្រះសហគមន៍រីកចម្រើន។ ដូច្នេះសម្រាប់យើងទាំងអស់ គ្រប់ទីកន្លែងដែលយើងនៅ ជាសញ្ញានៃជីវិតរបស់ព្រះសហគមន៍ដែលរីកចម្រើនបន្តិចម្តងៗ។ ដោយសារគ្រីស្តបរិស័ទម្នាក់ៗ ដែលបានទទួលខុសត្រូវ គាត់យកចិត្តទុកដាក់ ដើម្បីបន្តជំនឿ ដើម្បីឲ្យសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ទៅគ្រប់ទីកន្លែង។ ដូច្នេះ សម្រាប់យើងដែលជាគ្រីស្តបរិស័ទពីប៉ុន្មានឆ្នាំកន្លងមក យើងត្រូវការស្តាប់គម្ពីរនេះ សម្រាប់ជីវិតយើងសព្វថ្ងៃ **តើខ្ញុំធ្វើយ៉ាងមិចដើម្បីឲ្យទ្រព្យសម្បត្តិដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំរីកចម្រើន?** មានន័យថា ឲ្យខ្ញុំចេះទទួលខុសត្រូវយ៉ាងច្បាស់។ កុំឲ្យខ្ញុំទៅជាមនុស្សខ្ជិល មនុស្សរងងុយដេក អត់ដឹងអីសោះ! យើងជាមនុស្សម្នាក់ដែលព្រះជាម្ចាស់ស្រឡាញ់ យើងជាមនុស្សម្នាក់ដែលជីវិតមានតម្លៃ។ ដោយសារតែព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងមែនទែន ជាមនុស្សម្នាក់ដែលព្រះជាម្ចាស់បានជ្រើសរើស ណែនាំឲ្យយើងលែងជាមនុស្សទូទៅ តែណែនាំឲ្យយើងទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ យើងធ្វើ

យ៉ាងមិច ដើម្បីឲ្យជីវិតរបស់យើងចេញផ្លែយ៉ាងច្រើន ដោយការទទួលខុសត្រូវ គឺទទួលខុសត្រូវពីអ្វីដែលយើងបានទទួល។

ថ្ងៃនេះ សំណួរដែលខ្ញុំបានដាក់ "**តើអ្វីខ្លះដែលជាទ្រព្យសម្បត្តិនៅក្នុងជីវិតរបស់ខ្ញុំ?**" ព្រះជាម្ចាស់ឲ្យខ្ញុំទទួលខុសត្រូវ ខ្ញុំបានទទួលច្រើនខ្ញុំត្រូវទទួលខុសត្រូវច្រើន។ ប៉ុន្តែកុំឲ្យខ្ញុំកប់ កុំឲ្យខ្ញុំលាក់ កុំឲ្យខ្ញុំធ្វើអត់ដឹង អំពីអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំ។ កុំឲ្យយើងក្លាយជាអ្នកបម្រើទី៣ ជាមនុស្សខ្ជិល ដូច្នេះអត់មានផ្លែ គាត់មិនបានធ្វើឲ្យបាត់ប៉ុន្តែគ្មានផល។ យើងត្រូវការគិតអំពីទ្របញយសម្បត្តិរបស់យើងដែរ នៅក្នុងអត្ថបទទី២លោកប៉ូលនិយាយថា "**យើងមានគ្នាច្រើនរួមគ្នាជាព្រះកាយតែមួយ**" យើងគ្នាច្រើនតែយើងជាព្រះគ្រីស្តតែមួយ។ "**នៅក្នុងអង្គព្រះគ្រីស្តហើយ ម្នាក់ៗជាសរីរាង្គរបស់គ្នាទៅវិញទៅមក**" យើងមិនអាចបាត់នរណាម្នាក់ ដោយសាររូបកាយដែលមិនពេញលក្ខណៈមិនស្រួលទេ។ សម្រាប់យើងដែលជាព្រះកាយព្រះគ្រីស្ត យើងដឹងថារៀងៗខ្លួនសំខាន់ណាស់ ប្រសិនបើយើងបាត់ម្នាក់រូបកាយព្រះគ្រីស្តមិនពេញលក្ខណៈ។ យើងត្រូវទទួលខុសត្រូវ មិនទម្លាក់លើគេ កុំឲ្យយើងគិតថាខ្ញុំមិនធ្វើមេត្តាករុណា ដោយសារខ្ញុំមិនមែនជាសមាជិកក្រុមសង្គហៈ។ យើងជាសរីរាង្គឲ្យគ្នាទៅវិញទៅមក មានខ្លះជាដៃ មានខ្លះជាជើង មានខ្លះជាមាត់ មានខ្លះជាក្បាល...។

ខ្ញុំមាន២៣ចំនុចសម្រាប់ឲ្យបងប្អូនរិះគិតៈ

១ ប្រសិនបើបងប្អូនទទួលព្រះអំណោយទាន ខាងថ្លែងព្រះបន្ទូល ត្រូវថ្លែងឲ្យស្របតាមជំនឿ។

២ អ្នកណាទទួលព្រះអំណោយទានខាងបម្រើ ចូរបម្រើទៅ។

៣ អ្នកណាទទួលព្រះអំណោយទានខាងបង្រៀន ចូរបង្រៀនទៅ។

៤ អ្នកដែលលើកទឹកចិត្តបងប្អូន ចូរលើកទឹកចិត្តគេទៅ។

៥ អ្នកដែលចែករំលែកទ្រព្យរបស់ខ្លួន ចូរចែកដោយចិត្តស្មោះស។

៦ អ្នកដែលដឹកនាំ ចូរដឹកនាំដោយចិត្តខ្នះខ្នែង។

៧ អ្នកដែលចែកទានដល់ជនក្រីក្រ ចូរចែកឲ្យគេដោយចិត្តត្រេកអរ។

៨ ចូរមានចិត្តស្រឡាញ់ដោយឥតលាក់ពុតឡើយ។

៩ ចូរស្អប់ខ្ពើមនូវអ្វីៗដែលអាក្រក់ ហើយជាប់ចិត្តតែនឹងអ្វីដែលល្អវិញ។

១០ ចូរស្រឡាញ់រាប់អានគ្នាទៅវិញទៅមកទុកដូចជាបងប្អូនបង្កើត។

១១ ត្រូវលើកកិត្តិយសឲ្យគ្នាទៅវិញទៅមក ដោយចិត្តគោរព។

១២ ត្រូវឧស្សាហ៍ខ្នះខ្នែងកុំខ្ជិលច្រអូសឡើយ។
១៣ ត្រូវបម្រើព្រះអម្ចាស់ដោយចិត្តក្លៀវក្លា។
១៤ ចូរសប្បាយរីករាយដោយចិត្តសង្ឃឹម។
១៥ ចូរកាន់ចិត្តអត់ធ្មត់ក្នុងពេលមានទុក្ខលំបាក។
១៦ ចូរព្យាយាមអធិដ្ឋាន។
១៧ ត្រូវជួយទំនុកបម្រុងប្រជាជនដ៏វិសុទ្ធដែលខ្វះខាត។
១៨ ព្រមទាំងទទួលភ្ញៀវដោយរាក់ទាក់ផង។
១៩ ត្រូវជូនពរដល់អស់អ្នកដែលបៀតបៀនបងប្អូន ត្រូវជូនពរគេ កុំដាក់បណ្ដាសាគេឡើយ។
២០ ចូរអរសប្បាយជាមួយអស់អ្នកដែលអរសប្បាយ ចូរយំសោកជាមួយអស់អ្នកដែលយំសោក។
២១ ត្រូវមានចិត្តគំនិតចុះសម្រុងគ្នាទៅវិញទៅមក។
២២ មិនត្រូវមានគំនិតលើកតម្កើងខ្លួនឡើយ តែត្រូវចាប់ចិត្តនឹងអ្វីដែលទន់ទាបវិញ។
២៣ មិនត្រូវអួតខ្លួនថាជាអ្នកមានប្រាជ្ញាឡើយ។

នេះដើម្បីរៀបចំជីវិតរបស់យើង អ្វីដែលយើងទទួលឲ្យយើងធ្វើអស់ពីសមត្ថភាព យើងជាអ្នកដែលស្រឡាញ់អស់ពីចិត្ត យើងជាអ្នកដែលដើរតាមអ្វីដែលល្អ។ ព្រះសហគមន៍របស់យើងមានជីវិត ដោយសារយើងជាគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមកដូចបងប្អូនបង្កើត។ យើងត្រូវការលើកកិត្តិយសគ្នាទៅវិញទៅមក ឲ្យយើងទៅជាអ្នកបម្រើ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើង ឲ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គ និងឲ្យយើងទទួលខុសត្រូវខ្ពស់ ដោយដឹងថាយើងជាអ្នកបម្រើ។ យើងបំពេញគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ តាមព្រះហឫទ័យរបស់ព្រះអង្គ។

យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់វត្តិសាស្ត្រនៃព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់គ្នាទៅវិញទៅមក។ សូមព្រះអង្គជួយយើងឲ្យយើងយកចិត្តទុកដាក់បម្រើដោយទទួលខុសត្រូវយ៉ាងខ្ពស់ តាមសេចក្ដីត្រូវការរបស់ព្រះសហគមន៍ និងតាមអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ ដើម្បីធ្វើជាគ្រីស្តបរិស័ទដ៏អស្ចារ្យ ដោយសារព្រះជាម្ចាស់ជ្រើសរើសយើង យើងជាប្រជាជនដ៏វិសុទ្ធមានន័យថា យើងចូលនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ អាម៉ែន៕